# ល្ខោនចម្រុះ រឿង មហាភារតៈ/ភារតយុទ្ធ ឈុត «សន្តិករ យុធិស្ឋិរ»

វីរកថាសំខាន់និងជាវណ្ណកម្មពីរធំៗនៅក្នុងសិល្បៈខ្មែរ គឺរឿងរាមកេរ្តិ៍និងរឿងមហាភារតៈ និពន្ធដោយ វ្យាសៈ (Vyasa) ជារឿងដែលមានប្រភពចេញមកពីប្រទេសឥណ្ឌា និងមានអាយុកាលក្នុងចំណោមចាស់ជាងគេនៅលើពិភពលោក។

«មហាភារតៈ» មានន័យថា «រឿងដ៏អស្ចារ្យនៃត្រកូលក្សត្រភារតៈ»។[១] «ភារតៈ» ក៏ជាពាក្យមួយដែលជនជាតិឥណ្ឌាប្រើដើម្បីសម្គាល់សញ្ជាតិឥណ្ឌា ដូច្នេះគឺមានន័យថា «រឿងដ៏អស្ចារ្យនៃប្រទេសឥណ្ឌា»។[២] មានប្រភពខ្លះអះអាងថា ជារឿងដែលធំជាងគេរបស់មនុស្សជាតិ។[៣] រឿងនេះជារឿងដ៏វែង តាំងតែពីយុគសម័យវេទ ប្រមាណសតវត្សទី៩ មុនគ្រឹស្តសករាជ និងនៅក្នុងទម្រង់ចុងក្រោយនាយុគសម័យហ្គុបតា សតវត្សទី៤ នៃគ្រឹស្តសករាជ។[៤]

ដោយឡែកនៅកម្ពុជា បុព្វបុរសខ្មែរយើងបានឆ្លាក់រឿងមហាភារតៈ នៅលើថ្មនាមហាប្រាសាទអង្គរវត្តនិងបាយ័ន។ ឯនាពេលបច្ចុប្បន្ននេះ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងជំរុញលើកទឹកចិត្តឲ្យសិល្បករសិល្បការិនីនិងលោកគ្រូអ្នកគ្រូតម្ងើងស្នាដៃសិល្បៈទស្សនីយភាព ធ្វើការសិក្សាស្រាវជ្រាវលើរឿងមហាភារតៈ និងមហាភារតយុទ្ធដើម្បីរំលេចឡើងបន្ថែម ជាពិសេសពីលើរឿងរាមកេរ្តិ៍ និងរឿងឯទៀតៗដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌសិល្បៈទស្សនីយភាពខ្មែរបច្ចុប្បន្ន។

ល្ខោនចម្រុះ ជាប្រភេទល្ខោនដែលមានធាតុផ្សំចម្រុះ។ នៅក្នុងល្ខោនចម្រុះដែលខ្ញុំនឹងរៀបរាប់នៅពេលនេះ មានធាតុផ្សំ៖ ចាប៉ីដងវែង តន្ត្រីបុរាណនិងប្រពៃណី តន្ត្រីសំឡេងស្រាល (មានអ្នកដឹកនាំវង់តន្ត្រីផង) ការនិយាយបែបល្ខោននិយាយ និងអ្នកច្រៀងចម្រៀងមហោរី ដោយមានជំនួយសំឡេងសន្ធាប់ដោយស្គរធំ *(Bruitard)* និងការតុបតែង

[១] Fitzgerald 2007: 1; Nelson 2007: 1

[២] Nelson 2007: 1

[៣] Tokunaga 1994: 1

[៤] Tokunaga 1994: 1; Fitzgerald 2007: 1

ធាកទំនើបព្រមដោយភ្លើងពណ៌និងការបាញ់ផ្សែង ព្រមទាំងមានគ្រឿងកំដរជាឧបករណ៍ ទោល ប៉ីពកទៀតផង។

ខ្ញុំគួរធ្វើការកត់សម្គាល់លើចំណុចពីរសំខាន់ពាក់ព័ន្ធនឹងរឿងមហាភារតៈ ដែលជាសាច់រឿងធំទាំងមូល (១៨ សៀវភៅ) (មើលឯកសារលោក ធន់ ហ៊ិន (២០១០)) និងមួយទៀត គឺរឿងមហាភារតយុទ្ធ (៦/១៨ សៀវភៅ) (មើលឯកសារ ឧកញ៉ា ពិទូរ ឈឹម ក្រសេម (២០០៧)) ដែលគ្រាន់តែជាចំណែកមួយនៅក្នុងរឿងមហាភារតៈ។

ជាលើកទី១ ដែលខ្មែរយើងតម្លើងស្នាដៃរឿងមហាភារតយុទ្ធ (មហាភារតៈ) ខ្នាតធំ។ ឈុត «សន្តិករ យុធិស្ឋិរ» ដកស្រង់ពីរឿងមហាភារតយុទ្ធ «មហាសង្គ្រាម១៨ថ្ងៃ» ដោយ ១៨កងពល (៧ ទល់នឹង ១១) វាំង បាណ្ឌវៈក្សត្រ និង កោរវៈក្សត្រ តម្លើងនិងដឹកនាំដោយលោកគ្រូ សេង សំអាន នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សម្តែងលើកទី១ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលមហោស្រពចតុម្មុខ ក្រុងភ្នំពេញ។ នេះក៏ជាមោទក ភាពនិងព្រឹត្តិការណ៍សិល្បៈវប្បធម៌ប្រវត្តិសាស្ត្រមួយដែរ។ នេះជា «កម្មវិធីពិសេស» អបអរសាទរមហោស្រពសិល្បៈអាស៊ីក្រោមប្រធានបទ «សាមគ្គីភាពដើម្បីសន្តិភាព» នៅពេលព្រះរាជាណាចក្រកម្ពុជា ធ្វើជាម្ចាស់ផ្ទះ ជាមួយគ្នានឹងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ៕

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



## ឯកសារពិគ្រោះ

ជួន ណាត.

(១៩៦៧). *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ឈឹម ក្រសេម (ឧកញ៉ាទេពពិទូរ).

(២០០៧). *រឿងមហាភារតយុទ្ធ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ទូច គឹមស្រ៊ាង.

(២០១៩). *សទ្ទានុក្រមខ្មែរបាលីសំស្ក្រឹត*. ភ្នំពេញ: មូលនិធិអៀង (អៀង សុធារ៉ា)។

ធន់ ហ៊ិន (អ្នកប្រែសម្រួល).

(២០១០). *រឿងមហាភារតៈ*. ភ្នំពេញ: ធន់ ហ៊ិន។

ធន់ ហ៊ិន.

(២០០៥). *បទានុក្រមនៃរឿងរាមាយណៈ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ជន់ ហ៊ិន.

(២០០៣). *រាជសព្ទក្នុងភាសាខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

សំ សំអាង.

(២០២២). *រឿងមហាភារតយុទ្ធក្នុងសិល្បៈទស្សនីយភាពខ្មែរ*. AMS Khmer Civilization.

Fitzgerald, James L.

(1999). *The Story of the Mahabharata*. Knoxville, TN: University of Tennessee Press.

________.

(2007). *The Mahabharata: The Great Epic of India*. Chicago: University of Chicago Press.

Nelson, Richard (Trans.).

(2007). *The Mahabharata*. Farlex, Inc.

Tokunaga, Muneo.

(1994). *The Mahabharata*. Kyoto: HinduNet, Inc.